ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៤៣១៩ ប្រ.ក.

# ប្រកាស
## ស្ដីពី
## ការផ្ដល់បណ្ណបើកបរយានយន្តនគរបាលជាតិ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ស្ដីពីការប្រកាសឲ្យប្រើច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៧/០០២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្ដីពីការប្រកាសឲ្យប្រើច្បាប់ស្ដីពីវិសោធនកម្ម មាត្រា៨ មាត្រា៤០ មាត្រា៤១ មាត្រា៤៧ មាត្រា៤៨ មាត្រា៧៥ មាត្រា ៧៧ មាត្រា៨២ និងមាត្រា៩០ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ១** .

ត្រូវបានផ្ដល់បណ្ណបើកបរយានយន្តនគរបាលជាតិ សម្រាប់មន្ត្រីនគរបាលជាតិក្នុងការបើកបរយានយន្តបម្រើជំនាញគ្រប់ប្រភេទដែលជាទ្រព្យសម្បត្តិរដ្ឋ គ្រប់គ្រងដោយក្រសួងមហាផ្ទៃ។

**ប្រការ២** .

ប្រគល់សមត្ថកិច្ចជូនអគ្គស្នងការដ្ឋាននគរបាលជាតិក្នុងការសម្រេចផ្ដល់បណ្ណបើកបរយានយន្តនគរបាលជាតិ។

ទម្រង់បែបបទនីតិវិធីក្នុងការផ្ដល់ និងប្ដូរបណ្ណបើកបរយានយន្តនគរបាលជាតិ ត្រូវបានកំណត់ដោយសេចក្ដីណែនាំរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ។

**ប្រការ៣** .

លក្ខណៈសម្គាល់នៃបណ្ណបើកបរយានយន្តនគរបាលជាតិ មានដូចខាងក្រោម ៖

- ផលិតដោយជ័រផ្លាស្ទិចរឹង ពណ៌ខៀវខ្ចី ទំហំ ៨៦ មីលីម៉ែត្រ x ៥៤ មីលីម៉ែត្រ

- ផ្ទៃខាងមុខបណ្ណមានរំលេចរូបស្រមោលប្រាសាទអង្គរវត្ត រូបទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ពាក្យ " ព្រះរាជាណាចក្រកម្ពុជា និងបាវចនាជាតិ " ជាអក្សរជាតិ អង់គ្លេស និងរូបនិមិត្តសញ្ញារបស់ក្រសួងមហាផ្ទៃ រូបនិមិត្តសញ្ញារបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ពាក្យ "បណ្ណបើកបរយានយន្តនគរបាលជាតិ" ភាសាអង់គ្លេស "National Police Driving License" និងពាក្យ "អ្នកក្លែងបណ្ណបើកបរយានយន្តនេះនឹងត្រូវផ្តន្ទាទោសតាមច្បាប់"

- ផ្ទៃខាងក្រោយបណ្ណមានរំលេចរូបស្រមោលផែនទីនៃព្រះរាជាណាចក្រកម្ពុជា លេខសម្គាល់បណ្ណ រូបថតនគរបាលជាតិ ប្រភេទបណ្ណ គោត្តនាម និងនាម អត្តលេខ ថ្ងៃខែឆ្នាំកំណើត ភេទ អង្គភាព ឋានន្តរសក្តិ មុខតំណែង ថ្ងៃចេញបណ្ណ ថ្ងៃផុតកំណត់ និងមានលេខកូដ (MRZ Code) ។

ទម្រង់បណ្ណបើកបរយានយន្តនគរបាលជាតិ មានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៤ .**

បណ្ណបើកបរយានយន្តនគរបាលជាតិមាន០៤ប្រភេទដូចខាងក្រោម៖

- ប្រភេទ១ : ទោចក្រយានយន្ត ត្រីចក្រយានយន្ត ហៃអេម ប្រដេញ ល្បាត និងម៉ូតូកង់បួន
- ប្រភេទ២ : រថយន្តផ្ទុកចំនួនអ្នកជិះមិនលើសពី ២០ (ម្ភៃ) នាក់ រថយន្តសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ០,៧៥ (សូន្យក្បៀសចិតសិបប្រាំ) តោន រថយន្តដឹកសម្ភារ វត្ថុផ្សេងៗ ឬផ្ទុកឧបករណ៍បម្រើវិស័យជំនាញមិនលើសពី ៣,៥ (បីក្បៀសប្រាំ) តោន មានដូចជា ៖ រថយន្តអមភ្ញៀវ រថយន្តប្រដេញ រថយន្តល្បាត រថយន្តសង្គ្រោះ រថយន្តដឹកកងកម្លាំងដែលមានបំពាក់ភ្លើងសញ្ញា និងស៊ូរសព្ទពិសេស
- ប្រភេទ៣: រថយន្តផ្ទុកចំនួនអ្នកជិះលើសពី២០(ម្ភៃ) នាក់ រថយន្តដែលមានទម្ងន់ផ្ទុកសរុបអតិបរមាលើសពី ៣,៥ (បីក្បៀសប្រាំ) តោន មានដូចជា៖ រថយន្តពន្លត់អគ្គីភ័យ រថយន្តស្ទូច រថយន្តសណ្តោង រថយន្តដឹកឧបករណ៍ សម្ភារ រថយន្តដឹកយុទ្ធោបករណ៍ និងរថយន្តដឹកកងកម្លាំង
- ប្រភេទ៤: រថពាសដែក យានយន្តប្រឆាំងបាតុកម្ម យានយន្តបំពាក់យុទ្ធោបករណ៍ រថយន្តប្រយុទ្ធ និងរថយន្តរំដោះចំណាប់ខ្មាំង។

**ប្រការ៥.**

លក្ខខណ្ឌផ្សេងៗដែលទាក់ទងនឹងការផ្តល់បណ្ណបើកបរយានយន្តនគរបាលជាតិត្រូវកំណត់ដូចខាងក្រោម ៖

១- ចំពោះមន្ត្រីនគរបាលជាតិដែលមិនមានឯកទេសបើកបរយានយន្ត ត្រូវចូលរៀនឯកទេសបើកបរយានយន្ត និងបានប្រឡងជាប់ទាំងផ្នែកទ្រឹស្តី និងការបើកបរជាក់ស្តែង ។

ចំពោះមន្ត្រីនគរបាលជាតិដែលមានបទពិសោធន៍បើកបរយានយន្ត រយៈពេលយ៉ាងតិច ០៣(បី)ឆ្នាំ និងកំពុងបំពេញការកិច្ចបើកបរយានយន្តនគរបាលជាតិ ត្រូវឆ្លងការត្រួតពិនិត្យបទពិសោធន៍វាយតម្លៃសមត្ថភាព។

លក្ខខណ្ឌ និងនីតិវិធីបង្រៀន ការប្រឡង និងការត្រួតពិនិត្យបទពិសោធន៍វាយតម្លៃសមត្ថភាពបើកបរយានយន្តនគរបាលជាតិ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ។

២- ត្រូវបានផ្តល់បណ្ណបើកបរយានយន្តនគរបាលជាតិ ត្រឹមត្រូវតាមប្រភេទយានយន្តដូចមានចែងក្នុងប្រការ ៤ ខាងលើ។

៣- បណ្ណបើកបរយានយន្តនគរបាលជាតិប្រភេទ ៣ និងប្រភេទ ៤ ត្រូវបានផ្តល់ឲ្យមន្ត្រីនគរបាលជាតិមានអាយុយ៉ាងតិច ២២(ម្ភៃពីរ) ឆ្នាំ។

៤- សុពលភាពបណ្ណបើកបរយានយន្តនគរបាលជាតិ ត្រូវកំណត់ដូចខាងក្រោម៖

- រយៈពេល១០ (ដប់)ឆ្នាំ សម្រាប់បណ្ណបើកបរយានយន្តនគរបាលជាតិប្រភេទ១ និងប្រភេទ២
- រយៈពេល ៥ (ប្រាំ)ឆ្នាំ សម្រាប់បណ្ណបើកបរយានយន្តនគរបាលជាតិប្រភេទ៣ និងប្រភេទ៤។

**ប្រការ៦ .**

មន្ត្រីនគរបាលជាតិ ដែលកំពុងបំពេញភារកិច្ចបើកបរយានយន្តនគរបាលជាតិមានបទពិសោធន៍ក្នុងការបើកបររយៈពេលយ៉ាងតិច៣ឆ្នាំ ត្រូវបានត្រួតពិនិត្យវាយតម្លៃ និងផ្ដើមស្នើផ្ដល់បណ្ណបើកបរយានយន្តនគរបាលជាតិតាមប្រភេទយានយន្តដែលកំពុងបើកបរ។

**ប្រការ៧ .**

សាមីអង្គភាពនីមួយៗដែលបានស្នើសុំផ្តល់បណ្ណបើកបរយានយន្តនគរបាលជាតិ ដល់មន្ត្រីនគរបាលជាតិក្រោមឱវាទ ត្រូវបង់តម្លៃសេវាដូចខាងក្រោម៖

- បណ្ណបើកបរយានយន្តនគរបាលជាតិគ្រប់ប្រភេទ តម្លៃ ៥០ ០០០(ប្រាំម៉ឺន)រៀល
- ការប្តូរបណ្ណបើកបរយានយន្តនគរបាលជាតិគ្រប់ប្រភេទ តម្លៃ ៤០ ០០០(បួនម៉ឺន)រៀល។

ការកំណត់តម្លៃខាងលើនេះ អាចកែប្រែទៅតាមស្ថានភាពជាក់ស្តែង ក្រោយពីមានសំណើរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ និងមានការឯកភាពពីក្រសួងមហាផ្ទៃ ។

**ប្រការ៨ .**

អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវលើកគម្រោងស្នើសុំចំណាយលើការបង្រៀន និងការប្រឡងយកបណ្ណបើកបរយានយន្តនគរបាលជាតិទៅក្នុងគម្រោងចំណាយប្រចាំឆ្នាំនីមួយៗ ដើម្បីស្នើសុំការសម្រេចពីក្រសួងមហាផ្ទៃ។

**ប្រការ៩ .**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា ប្រធានក្រុមប្រឹក្សានីតិកម្ម ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ ប្រធាននាយកដ្ឋាននគរបាលចរាចរណ៍និងសណ្តាប់ធ្នាប់សាធារណៈ ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ[illegible] ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

<u>កន្លែងទទួល</u> ៖

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឧបនាយករដ្ឋមន្ត្រី
-ក្រសួងសាធារណការ និងដឹកជញ្ជូន
-ដូចប្រការ ៩ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ